ASIAN-PACIFIC
CONGRESS on EVANGELISM
SYDNEY 2027

A MINISTRY OF BILLY GRAHAM EVANGELISTIC ASSOCIATION

**ព្រឹត្តិបត្រព័ត៌មាន**

**សម្រាប់ការប្រើប្រាស់ភ្លាមៗ**

**ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៦**

# គ្មានសេចក្តីខ្មាសចំពោះដំណឹងល្អ៖ លោក ហ្វ្រែងគ្លីន ហ្គ្រាហាំ (Franklin Graham) រៀបចំ *មហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកស្តីពីការផ្សាយដំណឹងល្អ* ដោយមានវាគ្មិន ២១ រូប មកពី ១០ ប្រទេស

*អ្នកដឹកនាំក្រុមជំនុំមកពីជាង ៥០ ប្រទេស និងដែនដីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក នឹងទទួលបានការលើកទឹកចិត្ត និងការបំពាក់បំប៉ន ដើម្បីបន្តការប្តេជ្ញាចិត្តក្នុងការផ្សាយដំណឹងល្អតាមគោលការណ៍ព្រះគម្ពីរដោយចិត្តក្លាហាន*

ក្នុងរយៈពេលមួយឆ្នាំគត់ខាងមុខនេះ *មហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកស្តីពីការផ្សាយដំណឹងល្អ* របស់សមាគមផ្សាយដំណឹងល្អ ប៊ីល្លី ហ្គ្រាហាំ នឹងប្រព្រឹត្តទៅនៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី។

លោក ហ្វ្រែងគ្លីន ហ្គ្រាហាំ ជាប្រធាន និងជាអគ្គនាយកសមាគមផ្សាយដំណឹងល្អ ប៊ីល្លី ហ្គ្រាហាំ បានមានប្រសាសន៍ថា៖ «នេះជាពេលវេលាដ៏សំខាន់សម្រាប់ក្រុមជំនុំក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលជាទីជម្រកនៃប្រជាជនភាគច្រើនលើសកលលោក

និងជាទីដែលមានមនុស្សភាគច្រើនលើសលប់មិនដែលបានឮព្រះនាមព្រះយេស៊ូវគ្រីស្ទ។ យើងកំពុងប្រមូលផ្តុំអ្នកផ្សាយដំណឹងល្អក្នុងតំបន់នេះ ដើម្បីធ្វើឱ្យប្រាកដថាមនុស្សគ្រប់ជំនាន់បានឮដំណឹងល្អថា ព្រះជាម្ចាស់ស្រឡាញ់ពួកគេ ហើយទ្រង់បានចាត់ព្រះយេស៊ូវគ្រីស្ទ ជាព្រះបុត្រារបស់ទ្រង់ឱ្យមកសង្គ្រោះយើងពីបាប»។

*មហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកស្តីពីការផ្សាយដំណឹងល្អ* រំពឹងថានឹងប្រមូលអ្នកដឹកនាំគ្រីស្ទបរិស័ទចំនួន ២,៤00 រូបមកពីទូទាំងតំបន់ ឱ្យមកជួបជុំគ្នានៅក្នុងទីក្រុងស៊ីដនី នាថ្ងៃទី២៤-២៦ ខែសីហា ឆ្នាំ២០២៧។ ក្នុងរយៈពេលបីថ្ងៃ មាន ១០ ភាសា មានវាគ្មិន និងអ្នករួមចំណែក ២១ រូប មកពីប្រទេសអូស្ត្រាលី ទ្វីបអាស៊ី ប្រទេសនូវែលសេឡង់ ទ្វីបអឺរ៉ុប សហរដ្ឋអាមេរិក ប្រទេសកាណាដា តំបន់មជ្ឈិមបូព៌ា និងទ្វីបអាហ្វ្រិក នឹងផ្តោតលើប្រធានបទក្នុងកណ្ឌគម្ពីររ៉ូម ១:១៦ — គ្មានសេចក្តីខ្មាសចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។

លោកគ្រូ បណ្ឌិត យ៉ុងហ៊ុន លី (Revd Younghoon Lee, Ph.D.) ជាគ្រូគង្វាលរៀមច្បងនៃក្រុមជំនុំដំណឹងល្អសព្វគ្រប់ យ៉ូអ៊ីដូ (Yoido Full Gospel Church) ក្នុងទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង ហើយក៏ជាវាគ្មិនសំខាន់មួយរូប បានមានប្រសាសន៍ថា៖ «នៅក្នុងគ្រាដែលអ្នកជឿជាច្រើននាក់មានអារម្មណ៍ថាឯកោក្នុងជំនឿរបស់ខ្លួន ការជួបជុំដូចជា*មហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកស្តីពីការផ្សាយដំណឹងល្អ* បានរំលឹកយើងថា យើងមិនមែននៅតែម្នាក់ឯងនោះឡើយ ហើយថែមទាំងកសាងការត្រាស់ហៅខាងបេសកកម្មរបស់យើងឡើងវិញសម្រាប់មនុស្សជំនាន់ក្រោយផងដែរ។ ទោះបីជាមានការប្រឈមមុខនឹងលោកិយនិយម និងការអសកម្មខាងព្រលឹងវិញ្ញាណយ៉ាងណាក៏ដោយ ក៏ដំណឹងល្អនៅតែមានឱកាសថ្មីៗដើម្បីឈោងចាប់មនុស្សជំនាន់ក្រោយ និងប្រជាជាតិនានាដែរ។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា មហាសន្និបាតនេះនឹងលើកទឹកចិត្តដល់អ្នកជឿ និងបញ្ឆេះចិត្តឆេះឆួលសាជាថ្មី សម្រាប់ការផ្សាយដំណឹងល្អនៅទូទាំងតំបន់»។

លោកបណ្ឌិត ហ្គារី មីលឡារ (Dr. Gary Millar) ជានាយកមហាវិទ្យាល័យទេវវិទ្យា ឃ្វីនស្លែន (Queensland Theological College) និងជាសហស្ថាបនិកនៃសម្ព័ន្ធដំណឹងល្អអូស្ត្រាលី (The Gospel Coalition Australia) ហើយក៏ជាវាគ្មិនសំខាន់មួយរូប បានមានប្រសាសន៍ថា៖ «ការទទួលខុសត្រូវក្នុងការនាំយកដំណឹងល្អនៃព្រះអម្ចាស់យេស៊ូវទៅគ្រប់ប្រជាជាតិក្នុងគ្រប់ជំនាន់ គឺជាបន្ទុកដ៏ធ្ងន់ធ្ងរ និងគួរឱ្យកោតស្ញប់ស្ញែង ប៉ុន្តែមិនអាចគេចវេសបានឡើយ។ ប្រសិនបើយើងយកចិត្តទុកដាក់លើការងារនេះដោយចិត្តមុតមាំ នោះយើងពិតជាត្រូវការគ្នាទៅវិញទៅមកយ៉ាងក្រៃលែង។ *មហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកស្តីពីការផ្សាយដំណឹងល្អ* គឺជាឱកាសដ៏ប្រពៃដែលចំពេលវេលាល្អ ដើម្បី លើកទឹកចិត្តគ្នាទៅវិញទៅមកឱ្យបន្តទៅមុខ ហើយរក្សាដំណឹងល្អជាកិច្ចការចំពោះមុខ និងជាកិច្ចការចម្បង ក្នុងខណៈដែលយើងរកវិធីឈោងចាប់ផ្នែកផ្សេងទៀតនៃពិភពលោករបស់យើងមកថ្វាយព្រះគ្រីស្ទ»។

ការប្រគុំតន្ត្រីពិសេសនៅក្នុង *មហាសន្និបាតអាស៊ីប៉ាស៊ីហ្វិកស្តីពីការផ្សាយដំណឹងល្អ* នឹងសម្តែងជូនដោយលោក ម៉ាយខល ដាប់បេលយូ ស្មីត (Michael W. Smith) ដែលជាម្ចាស់ពានរង្វាន់ ហ្គ្រាមី (Grammy

Award) បីសម័យកាល រួបជាមួយសិល្បៈករជាច្រើនរូបទៀត។

សមាគមផ្សាយដំណឹងល្អ ប៊ីល្លី ហ្គ្រាហាំ នឹងផ្តល់ជូនចំអាហារ និងរៀបចំកន្លែងស្នាក់នៅទាំងអស់សម្រាប់អ្នកចូលរួម ។ ការចុះឈ្មោះសម្រាប់មហាសន្និបាតនេះគឺធ្វើឡើងដោយឥតគិតថ្លៃ ហើយចូលរួមបានតែតាមរយៈការអញ្ជើញប៉ុណ្ណោះ។ ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់គេហទំព័រ SydneyCongress.com។

## បញ្ជីឈ្មោះវាគ្មិន និងអ្នករួមចំណែក

- **សហរដ្ឋអាមេរិក | លោកគ្រូ ហ្វ្រែងគ្លីន ហ្គ្រាហាំ** (Revd Franklin Graham) ជាប្រធាន និងជានាយកប្រតិបត្តិនៃសមាគមផ្សាយដំណឹងល្អ ប៊ីល្លី ហ្គ្រាហាំ និងអង្គការ សាម៉ារីតាន់ ភឺស (Samaritan's Purse)
- **អូស្ត្រាលី | ប្រធានក្រុមអភិបាល កានីស្កា រ៉ាហ្វេល** (Kanishka Raffel) ជាប្រធានក្រុមអភិបាលនៃភូមិភាគក្រុមជំនុំ អង់គ្លីខិន ប្រចាំក្រុងស៊ីដនី (Anglican Diocese of Sydney)
- **កូរ៉េខាងត្បូង | លោកគ្រូ បណ្ឌិត យ៉ុងហ៊ុន លី** (Revd Younghoon Lee, Ph.D.) ជាគ្រូគង្វាលរៀមច្បងនៃក្រុមជំនុំដំណឹងល្អសព្វគ្រប់ យ៉ូអ៊ីដូ (Yoido Full Gospel Church) ក្នុងទីក្រុងសេអ៊ូល
- **សិង្ហបុរី | លោកគ្រូ អេដម៉ុន ចាន់** (Revd Edmund Chan) ជាស្ថាបនិក និងជាអ្នកប្រឹក្សាផ្នែកភាពជាអ្នកដឹកនាំនៃសម្ព័ន្ធភាពសកល នៃក្រុមជំនុំបង្កើតសិស្សដោយចេតនា (Global Alliance of Intentional Disciple-making Churches)
- **តៃវ៉ាន់ | លោកគ្រូ បណ្ឌិត ជេមស៍ ហាត់សិន ថេល័រ** ទី៤ (Revd Dr. James Hudson Taylor IV) ជាប្រធានវិទ្យាស្ថានទេវវិទ្យានៃការផ្សាយដំណឹងល្អនៅប្រទេសចិន (China Evangelical Seminary) និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអង្គការ អូអិមអេហ្វ អន្តរជាតិ (OMF International)
- **សហរដ្ឋអាមេរិក | លោកស្រី ស៊ីស៊ី ហ្គ្រាហាំ លីនឈ៍** (Cissie Graham Lynch) ជាវាគ្មិន និងជាពិធីការិនីនៃកម្មវិធីផ្សាយ "ឥតភ័យខ្លាច" ("Fearless" podcast)
- **ប្រ៊ុយណេ | លោកគ្រូ បណ្ឌិត ភីធើរ ឈីន** (Revd Dr. Peter Chin) ជាលេខាធិការនៃសម្ពន្ធភាពក្រុមជំនុំព្រះជាម្ចាស់នៅតំបន់អាស៊ីអាគ្នេយ៍ (Southeast Asia AG Fellowship) និងជាអគ្គអធិការនៃក្រុមជំនុំព្រះជាម្ចាស់នៅប្រទេសប្រ៊ុយណេ
- **ប្រទេសនូវែលហ្សេឡង់ | លោកបណ្ឌិត រ៉ូបឺត សៀគីម៉ូទូ** (Dr. Robert Siakimotu) ជាអ្នកផ្សាយដំណឹងល្អជាមួយអង្គការអូផិន អ៊ែរ ខែមផេនន័រ (Open Air Campaigners) និងជាសហស្ថាបនិកនៃអង្គការព័ន្ធកិច្ច ប៉ូលីនេស៊ី (Polynesian Ministries)

- **សហរដ្ឋអាមេរិក ၊ លោកបណ្ឌិត ម៉ាក អិម យ៉ាប្រូ** (Dr. Mark M. Yarbrough) ជាប្រធានវិទ្យាស្ថានទេវវិទ្យានៅទីក្រុងដាឡាស (Dallas Theological Seminary)
- **កាណាដា ၊ លោកគ្រូ ឆាលស៍ ប្រាយស៍** (Revd Charles Price) ជាអ្នកផ្សាយដំណឹងល្អ និងជាប្រធានព័ន្ធកិច្ចនៃក្រុមជំនុំប្រជាជន (The Peoples Church)
- **ប្រទេសអូស្ត្រាលី ၊ លោកបណ្ឌិត ហ្គារី មីលឡារ** (Dr. Gary Millar) ជានាយកមហាវិទ្យាល័យទេវវិទ្យាឃ្វីនស្លេន (Queensland Theological College) និងជាសហស្ថាបនិកនៃសម្ព័ន្ធដំណឹងល្អអូស្ត្រាលី (The Gospel Coalition Australia)
- **សហរដ្ឋអាមេរិក** ၊ លោកគ្រូ វិល ហ្គ្រាហាំ (Revd Will Graham) ជាអ្នកផ្សាយដំណឹងល្អ និងជាអនុប្រធានប្រតិបត្តិនៃសមាគមផ្សាយដំណឹងល្អ ប៊ីល្លី ហ្គ្រាហាំ
- **អ៊ីរ៉ង់/ចក្រភពអង់គ្លេស ၊ លោក រ៉ាស៊ីន ស៊ូដម៉ានដ៍** (Rashin Soodmand) ជាសហស្ថាបនិកនៃព័ន្ធកិច្ចថតឆ៍ (Torch Ministries) ជាអ្នកនិពន្ធ និងជាវាគ្មិនអន្តរជាតិ
- **អូស្ត្រាលី ၊ ប្រធានក្រុមអភិបាល គ្លេន ដេវីស** (Archbishop Glenn Davies) ជាប្រធានក្រុមអភិបាលនៃភូមិភាគក្រុមជំនុំ សាយថឺន ក្រូស (Diocese of the Southern Cross) នៃក្រុមជំនុំ អង់គ្លីខិនប្រចាំប្រទេសអូស្ត្រាលី (Anglican Church of Australia)
- **សហរដ្ឋអាមេរិក ၊ លោកបណ្ឌិត ស្គីប ហៃស៊ិក** (Dr. Skip Heitzig) ជាគ្រូគង្វាលនៃក្រុមជំនុំ កាល់វ៉ារី ឆាភែល (Calvary Chapel) នៅក្រុងអាល់ប៊ូឃើឃី រដ្ឋញូវម៉ិកស៊ិក (Albuquerque, New Mexico)
- **ចក្រភពអង់គ្លេស ၊ លោកបណ្ឌិត គ្រីស ស៊ីនឃីនសុន** (Dr. Chris Sinkinson) ជាជំនួយការប្រធានព័ន្ធកិច្ចនៃក្រុមជំនុំ ឡានស៍ដោន (Lansdowne Church) និងជាប្រធានសាលាសម្រាប់ការបង្កើតសិស្ស (The School for Discipleship)
- **អូស្ត្រាលី ၊ លោកស្រី ម៉ាហ្គារ៉េត ខូត** (Margaret Court) ជាស្ថាបនិកនៃព័ន្ធកិច្ច ម៉ាហ្គារ៉េត ខូត (Margaret Court Ministries) និងជាអតីតកីឡាការិនីវាយកូនបាល់ (Tennis) ចំណាត់ថ្នាក់លេខ១ក្នុងពិភពលោក
- **សហរដ្ឋអាមេរិក ၊ លោកគ្រូ ហ្គ្រេក ឡូរី** (Revd Greg Laurie) ជាអ្នកផ្សាយដំណឹងល្អ និងជាគ្រូគង្វាលរៀមច្បងនៃក្រុមជំនុំចម្រូត សម្ព័ន្ធភាព គ្រីស្ទាន (Harvest Christian Fellowship)
- **ស៊ូដង់ខាងត្បូង ၊ លោកអភិបាល ចេមស៍ ឡាហ្គូស អាឡិចសាន់ឌឺ** (James Lagos Alexander) ជាប្រធានអភិបាលនៃក្រុមជំនុំ អាហ្វ្រិក អ៊ិនឡែន (African Inland Church)
- **អូស្ត្រាលី ၊ លោកស្រី មីសែល ភៀស** (Michelle Pearse) ជាអគ្គនាយិកានៃអង្គការ អូស្ត្រាលី គ្រីស្ទានឡប់ប៊ី (Australian Christian Lobby)

- **សហរដ្ឋអាមេរិក | លោកបណ្ឌិត ដេវីឌ ព្រូស** (Dr. David Bruce) ជាអតីតជំនួយការប្រតិបត្តិរបស់លោក ប៊ីលី្ល ហ្គ្រាហាំ និងជាអនុប្រធានប្រតិបត្តិនៃមជ្ឈមណ្ឌលរក្សាទុកឯកសារ និងស្រាវជ្រាវ ប៊ីលី្ល ហ្គ្រាហាំ (Billy Graham Archive and Research Center)

**ចុងបញ្ចប់**

**កំណត់ត្រាសម្រាប់អ្នកត្រួតពិនិត្យអត្ថបទ**

**ឱកាសសម្រាប់សារព័ត៌មាន**

- ទាញយក រូបថត និងវីដេអូ ចេញពីកញ្ចប់ព័ត៌មាន (Press kit) ហើយពិនិត្យមើលបញ្ជីឈ្មោះប្រទេស និងដែនដី ដែលចូលរួមក្នុងមហាសន្និបាត៖ Media.BillyGraham.org/Asian-Pacific-Congress-on-Evangelism
- យើងសូមទទួលស្វាគមន៍អ្នកសារព័ត៌មានក្នុងការចុះឈ្មោះចូលរួមមហាសន្និបាត ដែលនឹងប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលសន្និបាតអន្តរជាតិស៊ីដនី (International Convention Centre Sydney - ICC Sydney), 14 Darling Drive, Sydney NSW 2000។
- អ្នកសារព័ត៌មានអាចចុះឈ្មោះ ឬចូលរួមវគ្គនានាដោយមិនតម្រូវឱ្យបង់ប្រាក់អ្វីឡើយ ហើយអាហារក្នុងអំឡុងពេលមហាសន្និបាតក៏ឥតគិតថ្លៃដែរ។
- សូមទាក់ទង media@billygraham.org ដើម្បីបញ្ជាក់អំពីការចូលរួម (RSVP) ឬសម្រាប់ព័ត៌មានបន្ថែម។

## ប្រវត្តិរបស់សមាគមផ្សាយដំណឹងល្អ ប៊ីលី្ល ហ្គ្រាហាំ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក

សមាគមផ្សាយដំណឹងល្អ ប៊ីលី្ល ហ្គ្រាហាំ ត្រូវបានបង្កើតឡើងដោយលោក ប៊ីលី្ល ហ្គ្រាហាំ ក្នុងឆ្នាំ១៩៥០ ហើយបាន និងកំពុងផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទនៅជុំវិញពិភពលោក។ លោក ប៊ីលី្ល ហ្គ្រាហាំ មានសេចក្តីស្រឡាញ់ និងការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះតំបន់អាស៊ីប៉ាស៊ីហ្វិក ជាទីដែលលោកបាន ផ្សាយដំណឹងល្អទៅកាន់មនុស្សជាង ១៣ លាននាក់ នៅក្នុងយុទ្ធនាការផ្សាយដំណឹងល្អទ្រង់ទ្រាយធំចំនួន ៣៥ លើក។ ព្រឹត្តិការណ៍ផ្សាយដំណឹងល្អនៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ រយៈពេល ៥ ថ្ងៃជាប្រវត្តិសាស្ត្រក្នុងឆ្នាំ ១៩៧៣ ដែលមានអ្នកចូលរួមជាង ៣ លាននាក់ គឺជាព្រឹត្តិការណ៍ដ៏ធំបំផុតរបស់លោក។ ពេលលោកបានមក ដល់ទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ក្នុងឆ្នាំ១៩៥៩ មានមនុស្សប្រមាណ ៩៨០ ០០០ នាក់បានចូលរួមពេញ កីឡដ្ឋាន ដែលជាការបង្កើតកំណត់ត្រាមានចំនួនអ្នកចូលរួមច្រើនបំផុតនៅក្នុងទីក្រុងនេះ។ ក្នុងអំឡុងពេល នៃការទស្សនកិច្ចនោះដែរ លោក ហ្គ្រាហាំ បានទៅកាន់ទីក្រុងចំនួន ១១ នៅទូទាំងប្រទេសអូស្ត្រាលី និងប្រទេស

នូវែលសេឡង់ ដោយមានមនុស្សជាង ៣,៣ លាននាក់បានមកស្តាប់លោកផ្សាយដំណឹងល្អ ហើយមនុស្សជាង ១៤៦ ០០០ នាក់បានសម្រេចចិត្តទទួលជឿលើព្រះគ្រីស្ទ។

កូនប្រុសរបស់លោក គឺលោក ហ្វ្រែងគ្លីន ហ្គ្រាហាំ (Franklin Graham) បានផ្សាយដំណឹងល្អនៅតំបន់អាស៊ីប៉ាស៊ីហ្វិកចំនួន ៤១ លើក ក្នុងរយៈពេល ៣៣ ឆ្នាំកន្លងមកនេះ។ កាលពីពេលថ្មីៗនេះ លោក ហ្គ្រាហាំ ត្រូវបានគេអញ្ជើញឱ្យទៅផ្សាយដំណឹងល្អនៅក្នុងប្រទេសកម្ពុជា វៀតណាម និងឡាវ ដែលនៅទីនោះមានមនុស្សរាប់ពាន់នាក់បានឆ្លើយតបទទួលយកដំណឹងល្អ។ លោក ហ្គ្រាហាំ ក៏កំពុងរង់ចាំរៀបចំការផ្សាយដំណឹងល្អនៅទីក្រុងហាណូយ ប្រទេសវៀតណាម នាឆ្នាំ២០២៧ ខាងមុខនេះផងដែរ។

លោក វិល ហ្គ្រាហាំ (Will Graham) ដែលជាកូនប្រុសរបស់លោក ហ្វ្រែងគ្លីន ហ្គ្រាហាំ ក៏មានចិត្តឆេះឆួលចំពោះតំបន់នេះនៃពិភពលោកផងដែរ។ លោកបានរៀបចំយុទ្ធនាការផ្សាយដំណឹងល្អជាង ៣០ លើកនៅក្នុងបណ្ដាប្រទេស និងដែនដីនានាក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ហើយលោកបានអញ្ជើញទៅផ្សាយដំណឹងល្អនៅតំបន់ស៊ីកូគូ ប្រទេសជប៉ុន និងទីក្រុងអ៊ុយជេអុងប៊ូ ប្រទេសកូរ៉េ ក្នុងខែឧសភា ឆ្នាំ២០២៦។

ព័ន្ធការីដែលបានទទួលការបណ្តុះបណ្តាលខាងផ្នែកជួយមនុស្សមានវិបត្តិ នៃក្រុមការងារឆ្លើយតបឆាប់រហ័ស ប៊ីលី្ល ហ្គ្រាហាំ (Billy Graham Rapid Response Team) បានចុះបេសកកម្មជាង ៤០ លើកទៅកាន់បណ្ដាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដើម្បីផ្តល់ការថែទាំផ្លូវចិត្ត និងផ្លូវវិញ្ញាណដល់ប្រជាជនដែលរងគ្រោះដោយសារគ្រោះមហន្តរាយផ្សេងៗ ដូចជាគ្រោះរញ្ជួយដីឆ្នាំ២០១១ នៅទីក្រុងសេនដាយ ប្រទេសជប៉ុន គ្រោះខ្យល់ព្យុះឆ្នាំ២០១៤ នៅខេត្តស៊ីប៊ូ ប្រទេសហ្វីលីពីន និងគ្រោះរញ្ជួយដីឆ្នាំ២០២៦ នៅគូមាម៉ូតូ ប្រទេសជប៉ុន។

SearchforJesus.net ដែលជាគម្រោងផ្សាយដំណឹងល្អតាមប្រព័ន្ធអ៊ីនធឺណិតរបស់សមាគមផ្សាយដំណឹងល្អ ប៊ីលី្ល ហ្គ្រាហាំ (BGEA) បានផ្សាយទៅដល់មនុស្សជាង ១០០ លាននាក់នៅទូទាំងពិភពលោក និងបន្តផ្សាយដំណឹងល្អដល់មនុស្សរាប់សែននាក់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកជារៀងរាល់ឆ្នាំ។

**អំពីសមាគមផ្សាយដំណឹងល្អ ប៊ីលី្ល ហ្គ្រាហាំ**

សមាគមផ្សាយដំណឹងល្អ ប៊ីលី្ល ហ្គ្រាហាំ ត្រូវបានបង្កើតឡើងដោយលោក ប៊ីលី្ល ហ្គ្រាហាំ ក្នុងឆ្នាំ១៩៥០ ហើយបាន និងកំពុងផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទនៅជុំវិញពិភពលោក។ ចេញពីទីស្នាក់ការកណ្តាលរបស់ខ្លួននៅទីក្រុងឆាឡុត រដ្ឋខារ៉ូឡៃណាខាងជើង សមាគមផ្សាយដំណឹងល្អ ប៊ីលី្ល ហ្គ្រាហាំ បានដឹកនាំកិច្ចការបម្រើព្រះយ៉ាងទូលំទូលាយទាំងក្នុង និងក្រៅប្រទេស រួមមាន៖ យុទ្ធនាការផ្សាយដំណឹងល្អទ្រង់ទ្រាយធំ ដែលដឹកនាំដោយលោកគ្រូផ្សាយដំណឹងល្អ ហ្វ្រែងគ្លីន ហ្គ្រាហាំ និងលោក វិល ហ្គ្រាហាំ។ បណ្ណាល័យ ប៊ីលី្ល ហ្គ្រាហាំ បណ្តាញអធិស្ឋាន ២៤ម៉ោងក្នុងមួយសប្តាហ៍ ប៊ីលី្ល ហ្គ្រាហាំ។ ក្រុមការងារឆ្លើយតបឆាប់រហ័ស ប៊ីលី្ល ហ្គ្រាហាំ។ មជ្ឈមណ្ឌលបណ្តុះបណ្តាល ប៊ីលី្ល ហ្គ្រាហាំ នៅ The Cove (Billy Graham Training Center at The Cove) ដែលស្ថិតនៅក្រៅទីក្រុងអាសវីល រដ្ឋខារ៉ូឡៃណាខាងជើង។ SearchforJesus.net ជាគម្រោងផ្សាយដំណឹងល្អតាមប្រព័ន្ធអ៊ីនធឺណិត

ក្នុងការឈានទៅដល់មនុស្សរាប់ពាន់នាក់ឱ្យទទួលជឿលើព្រះគ្រីស្ទតាមអនឡាញ ព្រមទាំងការបម្រើដល់មនុស្សជាច្រើននាក់ទៀត តាមរយៈប្រព័ន្ធបោះពុម្ព ទូរទស្សន៍ ទូរសព្ទ វិទ្យុ និងអ៊ីនធឺណិត។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ [billygraham.org](https://billygraham.org)

A MINISTRY OF
BILLY GRAHAM
Evangelistic Association
*Always* Good News.